# ខ្មែរប៉ុស្ដិ៍
ឆ្នេរខាងកើត
**THE KHMER POST**
**EAST COAST**
**The Cambodian-American Biweekly News**
Email : Khmerpostusa@gmail.com
Call : 267-254-8758
VOLUME 04 ISSUE 52 January 29th - February 11th 2010


## ខួបកំណើតនៃ ម៉ាតាំង លូធ័រឃីង នៅវិទ្យាល័យហ្វីឡាដែលហ្វៀខាងត្បូង

**ដោយ : ពិន សំខុន**

០០ខួបកំណើតរបស់វីរៈបុរសស្បែកខ្មៅ ម៉ាតាំង លូទ័រឃីង នាឆ្នាំ ២០១០ នេះ បានត្រូវគេប្រារព្ធ នៅថ្ងៃច័ន្ទ ទី១៨ មករា ដូចរៀងរាល់ឆ្នាំ ។ កាលពីឆ្នាំ ២០០៩ ព្រលឹង និងស្រមោលនៃវីរៈបុរសនោះ បានសណ្ឋិតនៅលើសេតវិមានជាមួយនឹងជោគជ័យរបស់ ប៉ារ៉ាក អូបាម៉ា ជាជនស្បែកខ្មៅដំបូងបង្អស់ ដែលបានទទួលឋានៈខ្ពង់ខ្ពស់ជាប្រធានាធិបតីនៃសហរដ្ឋអាមេរិក ។ ភាពស្មើគ្នានៃមនុស្សគ្រប់សញ្ជាតិ និងពណ៌សម្បុរ បានលេចរូបរាងពិតប្រាកដ នាឱកាសដែលប្រធានាធិបតីថ្មី មានពណ៌សម្បុរស្បែកខ្មៅ បានចូលទៅកាន់កាប់អំណាចនៅសេតវិមាន នាខែមករាឆ្នាំមុនមក ។



**តទៅទំព័រទី ០៩**



ចៅហ្វាយក្រុង ម៉ាយកិល

## ខ្មែរជួយរំដោះទុក្ខប្រជាជនហៃទី


ពិធីអុចទៀននៅវត្តព្រះពុទ្ធរង្សី


ពិធីអុចទៀននៅវត្តសុរិយារង្សី

០០០សហគមន៍ខ្មែរ នៅវត្តសុរិយារង្សី បន្ទាប់មក នៅវត្តព្រះពុទ្ធរង្សី បានប្រារព្ធអុចទៀន នៅចំពោះមុខព្រះសង្ឃ ដែលព្រះអង្គសូត្រធម៌ "អនុច្ចាវដ្ត សង្ខារា ឧបត្តវេយធម៌នោ..." ដែលរំលឹកពីសង្ខាជាការមិនទៀងទាត់ ដើម្បីជួយរំលែកទុក្ខដល់ប្រជាជនជាតិហៃទី ដែលទើបរងគ្រោះដោយការរញ្ជួយផែនដីកំរិត៧ ដែលពុំមានចុងក្រោយ បណ្តាលឱ្យមនុស្សស្លាប់ និងបាត់ខ្លួន ២០ ម៉ឺននាក់ ហើយនឹងបាត់បង់ជម្រកជាង២លាននាក់ រាប់ទាំងប្រធានាធិបតី រ៉េណេ ប្រេវ៉ាល់ ផងដែរ ដែលវិមានប្រធានាធិបតី ក៏ត្រូវរលំបាក់បែករីឯសសផ្ទះរបស់លោកផ្ទាល់ក៏ត្រូវខូចខ្ទាំ ។

គ្រាន់តែឮដំណឹងពីការរញ្ជួយផែនដីនេះភ្លាម សហគមន៍អន្តរជាតិនាំគ្នាដឹកជញ្ជូនការសង្គ្រោះគ្រប់យ៉ាងទៅដល់ហៃទី តាំងពីថ្ងៃបន្ទាប់នៃគ្រោះមហន្តរាយ នាថ្ងៃទី១២ មករា ២០១០ ភ្លាមមក ។ បើទោះបីជា

**(តទៅទំព័រទី ១១)**

## រដ្ឋាភិបាលទាត់ចោលពាក្យតវ៉ាពីក្រុមគណកម្មាធិការ ព្រំដែនកម្ពុជានៅប៉ារីស



លោក ស៊ាន ម៉េងសែ

**❖ ដកស្រង់ពីភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៣ មករា ២០១០**

•••រដ្ឋាភិបាលខ្មែរ បានបដិសេធកាលពីថ្ងៃទី១២ មករា នៅក្នុងកិច្ចប្រជុំគណរដ្ឋមន្ត្រី នូវពាក្យតវ៉ារបស់គណកម្មាធិការព្រំដែនកម្ពុជា ដឹកនាំដោយលោក ស៊ាន ម៉េងសែ ពីក្រុងប៉ារីស ដែលបានថ្កោលទោសថា "ការបោះបង្គោលសីមាកម្ពុជា-វៀតណាម នោះជាទង្វើខុសច្បាប់" ។ បង្គោលសីមាដែលស្ថិតនៅលើដីប្រជាពលរដ្ឋនាខេត្តស្វាយរៀង បានត្រូវលោក សម រង្ស៊ី ក្រវែងចោល

**(តទៅទំព័រទី ១៥)**

សូមអញ្ជើញលោកអ្នកអានអត្ថបទជាភាសាអង់គ្លេស នៅទំព័រខាងក្នុង ដែលបានដកស្រង់ និងទទួលការអនុញ្ញាតឱ្យចុះផ្សាយពីសារព័ត៌មាន The Cambodia Daily នៅប្រទេសកម្ពុជា ។






អាម៉ុក
OPEN 7 DAYS A WEEK
9am-10pm
សូមស្វាគមន៍!
• អបអរ ថ្ងៃបុណ្យនៃសេចក្តីស្រឡាញ់!
• មានម្ហូបខ្មែរពិសេសៗជាច្រើនមុខ
• ម្ហូបថៃ ឡាវ និង ហ្វឺវៀតណាម
• មានទទួលសម្រាប់ពិធីជប់លាង
• ខួបកំណើត និង ពិធីផ្សេងៗ
• លោកអ្នកអាចទូរស័ព្ទមកកក់តុទុកមុនបាន
• មានកន្លែងចតរថយន្ត ដ៏ធំទូលាយ
20% OFF
DINNER
(min. order $20)
Cannot Combine
with Other Offer
Expire: 02/25/10
10% OFF
DINNER TAKE OUT
(min. order $15)
Cannot Combine
with Other Offer
Expire: 02/25/10
ភោជនីយដ្ឋានខ្មែរ
320 W OREGON AVENUE
(OREGON MARKET, SOUTH PHILLY)
Kavei
215.952.6688
Authentic Khmer • Thai • Lao • Vietnamese Phở

# ប្រធានបក្សសិទ្ធិមនុស្សឆ្លើយសំនួរ ហ្វីឡាដែលហ្វៀ


លោក កឹម សុខា

•••អ្នកចង់ដឹងពីការវិវឌ្ឍន៍នយោបាយនៅកម្ពុជា ប្រមាណ ៣០នាក់ បានស្តាប់ និងតាំងសំនួរទៅ លោក កឹម សុខា ប្រធានគណបក្សសិទ្ធិមនុស្ស នៅវត្តព្រះពុទ្ធរង្សី នាទីក្រុងហ្វីឡាដែលហ្វៀ កាលពីរសៀលថ្ងៃអាទិត្យ ។

ស្តីពីស្ថានការណ៍បយោបាយទូទៅ លោក កឹម សុខា បានសម្តែងពីភាពធ្ងន់ធ្ងររបស់ប្រទេសខ្មែរ ដឹកនាំតាមរបៀបផ្តាច់ការនៃគណបក្សប្រជាជនកម្ពុជា បានធ្វើឱ្យប្រជាពលរដ្ឋទទួលនូវការលំបាកវេទនាគ្រប់បែបយ៉ាង រាប់ទាំងពីភាពក្រីក្រ ភាពរងការគ្រោះថ្នាក់ដោយការរំលោភដោយប្រជាជាតិមានការគំរាមកំហែង ដោយសារសង្គ្រាមជាមួយនឹងប្រទេសជិតខាងថែមទៀត ។ លោកបន្តថា គណបក្សសិទ្ធិមនុស្ស ក៏ទទួលនូវការរំលោភសិទ្ធិយ៉ាងខ្លាំងក្លាណាស់ដែរ ដូចជានៅឱកាសបោះឆ្នោតចុងក្រោយនេះ មានការលួចបន្លំយកសន្លឹកឆ្នោតយ៉ាងជាក់ស្តែង ហើយការបែងចែកអាសនៈសភាទៀតសោត ក៏គ្មានតម្លាភាព និងស្មើភាពគ្នាដែរ ។

សំណួរជាច្រើនពុំសូវបានតាំងទៅលើនយោបាយជាតិទេ ពីសំណាក់អ្នកចូលរួមស្តាប់សន្និសីទ តែច្រើនតាំងទៅលើសម្ព័ន្ធភាពរវាងគណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី ទៅវិញ ។ សំនួរដ៏គួរឱ្យកត់សំគាល់មួយរបស់លោក អ៊ូ តៅ បានសម្តែងថា "ហេតុអ្វីក៏គណបក្សសិទ្ធិមនុស្ស ខ្លាចអីហ្នឹងរំលាយចូលទៅក្នុងគណបក្ស សម រង្ស៊ី តែម្តងទៅ ? " លោក សុខា បានតបថា "ពុំអាចធ្វើយ៉ាងដូច្នេះបានទេ គេត្រូវធ្វើសម្ព័ន្ធភាពក្នុងគោលនយោបាយរួមគ្នា ដែលទាំងពីរនាក់យល់ព្រម យើងបានធ្វើការចរចាគ្នា១ឆ្នាំមកហើយៗមានគំនិតស្របគ្នាមួយចំនួនហើយ នៅមានមួយចំនួនទៀតដែលពុំទាន់មានចម្លើយនៅឡើយ ហើយខ្ញុំនឹងចេញសេចក្តីថ្លែងការណ៍មួយ ពីសម្ព័ន្ធភាពនេះ នៅថ្ងៃទី១៥ ខែមករា ដែលជាខួបមួយឆ្នាំ នៃការ



ផ្តើមចរចាពីសម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យនេះ" ។ មានការបង្ហាញទស្សនៈថ្មីពីលោក កឹម សុខា ដែរ នាពេលនោះ ដោយលោកថ្លែងឆ្លើយតបនឹងសំនួរថា " គណបក្សទាំងពីរអាចរក្សាឈ្មោះឱ្យនៅដដែលបាន តែត្រូវឈរឈ្មោះបោះឆ្នោតនៅក្នុងឈ្មោះគណបក្សថ្មីរួមគ្នាមួយនៅលើបញ្ជីតែមួយ" គំនិតនេះ ខុសប្លែកលើកមុនបន្តិចត្រង់ចំណុច "គណបក្សទាំងពីរត្រូវរំលាយខ្លួនជាមុន ហើយចូលរួមក្នុងឈ្មោះគណបក្សថ្មីតែមួយ"។ នៅលើសំនួរមួយដែលថា "តើទស្សនកិច្ចលោកមកសហរដ្ឋអាមេរិកនេះមានបំណងមកថ្លែងតវ៉ាឱ្យលោក សម រង្ស៊ី អាចចូលទៅកម្ពុជាវិញ ដោយសុវត្ថិភាពដែរឬទេ ? ឬក៏គួរឱ្យលោក សម រង្ស៊ី នៅក្រៅស្រុកយ៉ាងនេះ មួយរយៈសិន " លោក កឹម សុខា តបថា "ដកអភ័យឯកសិទ្ធិពីតំណាងរាស្ត្រវាប៉ះពាល់ដល់សិទ្ធិនៃតំណាងរាស្ត្រទាំងអស់គ្នា ខ្ញុំបានសម្តែងនិងចេញសេចក្តីថ្លែងការណ៍ថ្កោលទោសច្រើនលើកច្រើនសារ តាំងពីគេទើបដកអភ័យឯកសិទ្ធិ លោក សម រង្ស៊ី រហូតមកដល់ពេលនេះ" ។

បរិយាកាសតាំងសំណួរចំពោះប្រធានគណបក្សសិទ្ធិមនុស្សមានការឆ្លើយឆ្លងកម្រិតខ្ពស់ ដោយវាគ្មិនច្រើនជាអ្នកតាមដានព្រឹត្តិការណ៍កម្ពុជា ជាជិតដិត ដូចជាលោកអ៊ំ គឹមហួត ឬ ហិនរី ហើយអតីតសមាជិកសភាខ្មែរ គឺលោក រស់ ហ៊ាន, សិនប៊ូ, ប្រាក់ វ៉ាន់នី បានធ្វើសន្និសីទមួយនេះ ពិភាក្សាគ្នាយ៉ាងមានប្រយោជន៍ជាទីបំផុត ។ លោក កឹម សុខា បានបញ្ចប់សន្និសីទនោះ ដោយស្នើទៅកាន់វាគ្មិនដែលមានបំណងជួយដល់កម្ពុជាវិញថា "ហ្វីឡាដែលហ្វៀ ជាតំបន់ដែលផ្តល់ការកកក្តៅ និងជំនួយដល់គណបក្សសិទ្ធិមនុស្សធំជាងគេបង្អស់ យើងបានទទួលជំនួយជាថវិកាពីខាងក្រៅ គឺជាការបរិច្ចាករបស់បងប្អូនយ៉ាងធំធេងសម្រាប់ប្រជាជាតិ តែគណបក្សសិទ្ធិមនុស្សនៅខ្វះធនធានគំនិត និងធនធានមនុស្សសម្រាប់ជាជំនួយដ៏សំខាន់បន្ថែមទៀត" លោកបន្តថា "ហ្វីឡាដែលហ្វៀ ជួយយើងខ្ញុំច្រើនជាងគេតែពុំមានតំណាងពីតំបន់នេះទៅឈរឈ្មោះនៅកម្ពុជានៅឡើយទេ "។

នៅចុងបញ្ចប់នៃសន្និសីទ២ម៉ោងរបស់លោក កឹម សុខា អង្គប្រជុំបានដឹងថា "ដើម្បីតែតម្រូវការសង្គមខ្មែរសព្វថ្ងៃនេះបាន ការរួមសម្បាច់នាឱកាសបោះឆ្នោតខាងមុខក្នុងសម្ព័ន្ធភាពអ្នកប្រជាធិបតេយ្យ គឺជាភាពចាំបាច់បំផុត ហើយលោក សម រង្ស៊ី អាចនឹងទទួលការគាំទ្រឱ្យក្លាយជាប្រធានសម្ព័ន្ធភាពទី១ នេះទៀតផង ៕

**ខ្មែរប៉ុស្តិ៍**

## មាតិការឿង (ទំព័រ)


១–WHYY CAMERA MADE និងស្ត្រីខ្មែរម្នាក់ស្លាប់.................ទំព័រទី០៣
២–ក្តីស្នេហ៍គ្មានទីបញ្ចប់ និងទឹកភ្នែកតែ៣ពែង.................ទំព័រទី០៤
៣–Port-au-Prince's Death.................ទំព័រទី១១
៤– The Cambodia Daily.................ទំព័រទី១៣
៥–ខ្មែរមានពូជ.................ទំព័រទី១៤
៦–នាទីប្រវត្តិសាស្ត្រ និងនាទីព្រះពុទ្ធសាសនា.................ទំព័រទី១៥
៧–ថ្ងៃ៧មករាជាថ្ងៃជោគជ័យ.................ទំព័រទី១៦
៨–ហោរាសាស្ត្រ.................ទំព័រទី១៧
៧–ទំព័រ Classify.................ទំព័រទី១៧



ភោជនីយដ្ឋាន ណាម វ៉ាង (ភ្នំពេញ)

Nam Vang Restaurant

571 Unit # 1 Adams Avenue. Philadelphia, Pa 19120
(inside Hong Kong Market) **(215) 742-9488**
Open 7 days a week from 9 a.m. – 9 p.m.

**បើក 7 ថ្ងៃក្នុងមួយអាទិត្យពីម៉ោង 9 ព្រឹក ដល់ 9 ល្ងាច**

**១_មុខជំនាញខាងម្ហូបខ្មែរយ៉ាងចំណាន ដូចជា:**
- គុយទាវភ្នំពេញ
- គុយទាវ ឬមី-ខគោ
- មីកន្ថាំង ឆារសាច់គោ
- មីកន្ថាំងឆារគ្រឿងសមុទ្រ
- បាយឆារគ្រប់មុខ
- សាច់គោអាំង ចង្កាក់ ជាមួយជ្រក់ល្ហុង

**២_មុខជំនាញម្ហូបវៀតណាមឈ្ងុយឆ្ងាញ់ ដូចជា:**
- នំបញ្ចុកទឹកត្រីពិសេស
- នំប៉័ងបាតេ ឬសាច់គោអាំង
- ខគោ នំប៉័ង ឬមី និងគុយទាវ
- បាយសរសាច់ជ្រូកអាំង ឬសាច់មាន់អាំង



រៀងរាល់ថ្ងៃលោកអ្នកអាចពិសាទឹកក្រឡុកគ្រប់រស់ជាតិផ្លែឈើ ដូចជា : ទុរេន ឬ អាវ៉ូកាដូ ហើយជាពិសេស មានទឹកអំពៅកិនស្រស់ៗ

# លិខិតថ្លែងអំណរគុណ

គណៈកម្មាធិការសាខាបក្សប្រជាជនកម្ពុជា ក្រុងហ្វីឡាដែលហ្វីយ៉ា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត
ចំពោះសប្បុរសជនបានចូលរួមជួយឧបត្ថម្ភថវិកាដល់យុទ្ធជនដែលឈរជើងការពារបូរណភាពទឹកដីខ្មែរនៅតំបន់ប្រាសាទព្រះវិហារ :









## បញ្ជីរាយនាមសប្បុរសជនដែលបានចូលបច្ច័យជួយដល់កងទ័ពដែលនៅការពារតំបន់ប្រាសាទព្រះវិហារ

| | |
|---|---|
| -ព្រះគ្រូ សែម សុខឃឿន ចៅអធិការវត្តខ្មែរបាលិលេយ្យ | $1000 |
| ១-ឯកឧត្តម សៀ កុសល់ និងលោកជំទាវ | ស្រាក្រហម ៤ប្រអប់ |
| ២-ឯកឧត្តម ហែម ហេង និងលោកជំទាវ | $800 |
| ៣-លោក និងលោកស្រី អ៊ូ សុវណ្ណ | $200 |
| ៤-លោក ថាច់ សុខា | $100 |
| ៥-លោក ឡេង ហាង | $100 |
| ៦-លោក និងលោកស្រី សុធំ កយ.ស៊ីនួន លំ | $50 |
| ៧-Christopher Chhern (child) | $20 |
| ៨-Angelina Chhern (child) | $20 |
| ៩-Anna Sophia Chhern (child) | $20 |
| ១០-ចូសស៊ីណា ញឹម (ក្មេង) | $20 |
| ១១-អាប៊ីហ្គិល សេង (ក្មេង) | $20 |
| ១២-អ្នកស្រី រីថា | $20 |
| ១៣-លោក ឡុង សូវ៉ាន់ | $40 |
| ១៤-លោក និងលោកស្រី សំ ទូច និង សុក វណ្ណី | $40 |
| ១៥-វ៉ូន ខុម | $5 |
| ១៦-សេង វី | $10 |
| ១៧-ផល្លា និង បុប្ផា | $10 |
| ១៨-សុខា ប្រាក់ | $20 |
| ១៩-ហួរ និង បូផាន់ | $20 |
| ២០-ហ៊ត ហេង | $20 |
| ២១-ឆៃ ហុង | $100 |
| ២២-លោក សេង | $50 |
| ២៣-ហ៊រ ចូ | $100 |
| ២៤-ជា ឆាយ | $40 |
| ២៥-គីម សេង | $50 |
| ២៦-ឈុតតារា ស្រី | $40 |
| ២៧-ចារ៉ូ បូ | |
| ២៨-ម៉េង ធាញ | |
| ២៩-ម៉ាឌី ជា | |
| ៣០-វីរយ៉ា ស៊ុសោភណ្ឌ និង សំអាត ជា | $400 |
| ៣១-វ៉ាន់ចាន ក្រូច | $100 |
| ៣២-លោក និងលោកស្រី ស៊ីថុន និងមិត្តភ័ក្តិពីកន្លែងធ្វើការ | $190 |
| ៣៣-លោក និងលោកស្រី ចេង សំអាត | $100 |
| ៣៤-លីលី | $50 |
| ៣៥-វឿន និង សាលីណា | $30 |
| ៣៦-ណារិទ្ធ | $45 |
| ៣៧-វិបុល ហេន | $25 |
| ៣៨-សូវណ្ណី ប្រាក់ | $30 |
| ៣៩-រ៉ា វុធ ស៊ី | $40 |
| ៤០-ម៉ៅ សំអឿន និង ម៉ៅ គីមលាង | $50 |
| ៤១-អ៊ុត ស៊ុធឿន និង វុទ្ធី | $50 |
| ៤២-អ៊ុ វ៉ាន | $20 |
| ៤៣-កុំ ហៀង | $20 |
| ៤៤-ហុន គៀង | $20 |
| ៤៥-ស៊ី យ៉ាន | $20 |
| ៤៦-អឿ មុំ និង យឿន លាង | $20 |
| ៤៧-វិសាល សុក (វ៉ាស៊ីនតុន ឌីស៊ី) | $50 |
| ៤៨-កែវ រីយ៉ាន | $100 |
| ៤៩-រីតី និង មីរៀម | $50 |
| ៥០-លៀន ពិល | $20 |
| ៥១-ប៊ុន ឡេង | $50 |
| ៥២-សាបាន អឿន និង បុប្ផា | $100 |
| ៥៣-សេង គីម | $40 |
| ៥៤-លោក និងលោកស្រី ពេង រុន | $30 |
| ៥៥-លោក និងលោកស្រី សុខ ឃុទ្ធ | $100 |
| ៥៦-លោក និងលោកស្រី ហាស់ បូរ៉ា | $100 |
| ៥៧-លោក និងលោកស្រី គីម សុភក្រ្ត | $100 |
| ៥៨-លោក និងលោកស្រី សុខ សារឿន | $50 |
| ៥៩-លោក និងលោកស្រី មូរ សំអូន | $100 |
| ៦០-លោក និងលោកស្រី ហុង វេន | $100 |
| ៦១-លោក និងលោកស្រី ថុង ផល្លា និង លីវ៉ាន់ដា លាក់ | $200 |
| ៦២-លោក និងលោកស្រី សៀក ស៊ុនទី | $150 |
| ៦៣-លោក លាង គីមឆាយ | $150 |
| ៦៤-លោក និងលោកស្រី ញ៉ឹម សុផា | $100 |
| ៦៥-លោក និងលោកស្រី ហួរ នីហៀង | $50 |
| ៦៦-លោក និងលោកស្រី ស សម្បត្តិ | $50 |
| ៦៧-លោក ជា សារុំ | $50 |
| ៦៨-លោក និងលោកស្រី សំ គាឡី | $150 |

គណៈកម្មាធិការសាខាបក្សប្រជាជនកម្ពុជាក្រុងហ្វីឡាដែលហ្វីយ៉ាសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត និងគោរពដល់ព្រះគ្រូចៅអធិការ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងក្មួយៗប្រកបដោយពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កើតមានជានិរន្តរ៍ ។

តមកទំព័រទី ០៦

# ទឹកតែ៣ពែង...

ឈ្មោះហៃជីអាលីស៍ (Haji Ali's) នាំទៅផ្ទះគាត់ ថែទាំនឹងព្យាបាលបំប៉នចំណីអាហារ ។ ហើយក្រោយពីបានក្រេបទឹកតែមួយពែងដំបូងគេ បានស្គាល់គ្នារួចហើយពែងទីពីរ គេបានសំណេះសំណាលគ្នា ទើបបានដឹងថាជនអាមេរិកាំងកំសត់នេះ មានបំណងឡើងរុករកកំពូលភ្នំ K2=ក២ នេះជាកីឡាម្យ៉ាងដែលជនបស្ចឹមប្រទេសច្រើនចូលចិត្តប្រថុយនឹងគ្រោះថ្នាក់ផ្សងព្រេង ម្យ៉ាងទៀតកំពូលភ្នំក២ទាបជាងកំពូលភ្នំហេមពានបន្តិច តែលំបាកឡើងជាង រហូតមកដល់ថ្ងៃនេះ មិនទាន់មានអ្នកណាម្នាក់បានឡើងទៅដល់ហើយស្គាល់កំពូលភ្នំនេះនៅឡើយ) ។ ក្រោយពីពែងតែទីបីជនជាតិបាគីស្ថានម្នាក់ជាអ្នកជំនួយការនាំផ្លូវទៅរកកំពូលភ្នំក២ របស់ Greg Mortenson (គ្រែគ) បានតាមរកឃើញជនវង្វេងផ្លូវនេះ ក៏បានជាសាក្សីបង្ហាញឱ្យឃើញថា ជនវង្វេងផ្លូវនេះជាជនដែលចង់ឡើងឱ្យដល់លើកំពូលភ្នំក២មែន ។ ដោយយល់ចិត្តថ្លើមគ្នាហើយ មេភូមិ ហៃជីអាលីស៍ តិតតែខំព្យាបាលអ្នកកំសត់នេះ រហូតដល់បានជាសះស្បើយ ។

ព្រឹកមួយនោះ គ្រែគ បានសម្លឹង និងស្តាប់នូវសម្លេងច្រៀងបទភ្លេងគោរពទង់ជាតិរបស់ប៉ាគីស្ថានពីក្រុមក្មេងមួយក្រុម ដែលបានប្រារព្ធកម្មវិធីចូលរៀនប្រចាំថ្ងៃរបស់គេ។ នេះជាថ្នាក់រៀនយ៉ាងគោកយ៉ាកបំផុត គឺក្មេងមួយក្រុមប្រមូលគ្នាមកអង្គុយក្រោមម្លប់ដើមឈើនៅលើដីផ្ទាល់។ ឯគ្រូបង្រៀនវិញត្រូវបានជួលពីភូមិឆ្ងាយមកបង្រៀនមួយអាទិត្យបានតែ៣ថ្ងៃប៉ុណ្ណោះ។ ក្រោយពីឈរត្រង់ខ្លួនគោរពទង់ជាតិមក ក្មេងទាំងនេះនាំគ្នាអង្គុយចុះផ្ទាល់ដីហើយនាំគ្នាសរសេរនូវតារាងមេលេខគុណ ដោយកាន់កំណាត់មែកឈើមួយតូចគូរលើដីជាក្តារខ្នួន។ មានសិស្សតិចណាស់ដូចនាង ជហ្វាហាន ចៅស្រីរបស់ប្រធានភូមិ ដែលមានក្តារខ្នួនធ្វើពីថ្មស្លេ្ដង ហើយសរសេរដោយដីភក់លុញឱ្យមូលជំនួសដីស។ ឃើញយ៉ាងនេះ គ្រែគ ស្រណោះក្នុងចិត្តគិតថា" ឱ!ស្រមៃសាកមើល ថាតើមានថ្នាក់ទីបួនណាមួយរបស់អាមេរិកាំងមកអង្គុយរៀនដោយគ្មានគ្រូ ហើយប្រកបដោយភាពសាត់ស្ងៀមដោយខ្លួនឯង ដើម្បីធ្វើការងារសិក្សាយ៉ាងនេះ? បេះដូងខ្ញុំហាក់ដូចកំពុងត្រូវគេចាប់រមួល អាណោចអាធ័មខ្លាំងណាស់ ខ្ញុំត្រូវតែធ្វើអ្វីម្យ៉ាង"។ តែធ្វើអីកើតបើខ្លួននៅសល់តែលុយបន្តិចបន្តួចគ្រប់តែជួលរថយន្តស៊ីពជិះទៅដល់កាបូលរដ្ឋធានីនៃប៉ាគីស្ថាន ហើយបន្តទិញសំបុត្រយន្តហោះត្រឡប់ទៅសហរដ្ឋ-អាមេរិកវិញតែប៉ុណ្ណោះ។ ហើយប្រហែលជាមានបញ្ហាអ្វីម្យ៉ាងនៅទីនោះទៀតផង ។ ឈរទីនោះក្បែរប្រធានភូមិសម្លឹងមើលកំពូលភ្នំក២ ដែលខ្លួនបរាជ័យក្នុងការប៉ុនប៉ងឡើងទៅដល់កំពូលនោះ គ្រែគ សន្យាជាមួយប្រធានភូមិថា" ខ្ញុំនឹងធ្វើសាលារៀនជូនមួយពេលខ្ញុំត្រឡប់មកវិញ ។





With the first cup of tea you are a stranger.
With the second...a friend.
With the third cup of tea, you are family.

(មានតទៅលេខក្រោយ)

Continued from page 05 WHYY CAMERA...

The camera made many of the students nervous. Some became shy and others off-balanced, contrasting with their usual rambunctiousness and perfect balance. Others stumbled over their movements or smiled nervously. After some time, the students slowly became accustomed to having the camera around and began to loosen up. They were able to focus a little bit better, and smile freely. The attention was welcomed among the students. Parents stood in the background, proudly admiring their children, grandchildren, nieces, and friends.

Having parents at the dance class's rehearsal was a welcomed change. A few parents usually stay for rehearsal, but many have errands to run while the students practice. Parents were able to take time out of their busy schedules and home lives to watch their little dancers. A warm feeling of positive pride and happiness filled CAGP's building on Friday when parents were able to witness everything their kids have been working so hard on. This dedication from students and parents alike are what will continue to spread and evolve Cambodian classical dance, as it has been spreading and evolving since the 7th century. With WHYY coming to CAGP's culture programs, the members of every community in the tri-state region (Southeastern Pennsylvania, Southern Jersey, and Delaware) will learm how important Cambodian classical dance is. It will also bring a sense of pride to many Cambodians in the area.

VIP Auto Center
បំរើសេវារថយន្ត
នឹងរថយន្តគ្រោះថ្នាក់ប៉ះទង្គិច

រោងជាងម៉ាស៊ីន
Check Engine Light Diagnostic
Electronic Wheel Alignment
Certified Enhanced Emission
Muffler & More

■Mechanic Service ■Body Repair ■State Inspection ■Towing Service

State Inspection $50

រោងជាងម៉ាស៊ីន
តម្រង់កង់ដោយកុំព្យូទ័រ
ការងារអេឡិចត្រូនិច
ធ្វើម៉ាស៊ីនត្រជាក់-ម៉ាស៊ីនក្តៅ
ត្រួតពិនិត្យខាងបញ្ចេញផ្សែង
ធ្វើម៉ូរ៉ស័រ
ធ្វើបំពង់ផ្សែង
បូមប្រេង
....នឹងធ្វើច្រើនទៀត



រោងជួសជុលតួរថយន្ត
គុណភាពខាងលាបថ្នាំ
ប្តូរគ្រឿងបន្លាស់ត្រឹមត្រូវ
ជួសជុលសម្បកឡាន
យើងអាចហៅទៅនិយាយជាមួយ អិនស្វ៊ីរិនជួសលោកអ្នកបាន
យើងវាយតម្លៃការងារឥតគិតថ្លៃ ។



រោងជួសជុលតួរថយន្ត
Expert Body Work
Fender & Paint Work
Frame Straightening
Insurance Specialists
មានជាងខ្មែរ

601W. Fisher Ave. Phila., PA 19120
Tel : 215-455-9999/215-329-4444/ Fax : 215-455-3757

# A.B.C MONEY TRANSACTION, INC

# $ ក្រុមហ៊ុនផ្ញើប្រាក់ A.B.C

## តម្លៃសំរាប់ផ្ញើទៅស្រុកខ្មែរ

| | | ភ្នំពេញ | តាមខេត្ត |
|---|---|---|---|
| ផ្ញើ $100 | យកកម្រៃ | $4.50 | $5.50 |
| $200 | យកកម្រៃ | $9.00 | $11.00 |
| $300 | យកកម្រៃ | $13.50 | $16.50 |
| $500 | យកកម្រៃ | $16.00 | $17.00 |
| $1000 | យកកម្រៃ | $25.00 | $26.00 |
| $1500 | យកកម្រៃ | $35.00 | $36.00 |
| $2000 | យកកម្រៃ | $42.00 | $43.00 |
| $2200 | យកកម្រៃ | $46.00 | $47.00 |



សូមកុំភ្លេចទាក់ទងការិយាល័យក្រុមហ៊ុន ABC ដែលនៅជិតលោកអ្នក ប្រសិនបើមានបំណងចង់ផ្ញើប្រាក់ទៅស្រុកខ្មែរ ឬក៏ទូរស័ព្ទមកយើងតាម

### នៅរដ្ឋ VIRGINIA សូមទាក់ទង

**ABC MONEY TRANSATION ,INC.**

8 locations to serve you in Virginia

- 6757 Willson Blvd.-Ste.#25 Tel : 703.534.2600
- 4291 Holland Rd-Ste.#111 Tel : 757.474.9400
- 10428 Ridgefield Pkwy Tel : 804-740-2454
- 2519 W . Mercury Blvd . Tel : 757.265.6305
- 23520 Overland Dr. Tel : 703.661.6666
- 6314 Rigsby Rd. Tel : 804.288.2988
- 7252 Arlingston Blvd . Tel : 703.641.0778
- 6217 W. Broad St. Tel : 804.288.6988

**ARIZONA**
- 4215 N 19th Ave. . Tel : 602.266.6744

**GEOERGIA**
- 4897 Buford Hwy. Ste. 202. Tel: 770.457.7888

**ILLINOIS**
- 4871 N. Broadway . Tel :773.989.7332

**MASSACHUSETTE**
- 996 Dorchester Ave. Tel:617.825.9380
- 1365-1377 Dorchester Ave. -Ste.4,Froor 1 .Tel : 617.265.4600

**MINNESOTA**
- 2718 Nicollet Ave . S.- Ste. 102 B
- Tel : 612.871.4731
- 6350 Brooklyn Blvd . Tel : 763.503.3947

**NORTH CAROLINA**
- 3000 Central Ave. Ste . #9 . Tel : 704-532-4420

**OREGON**
- 6908 N.E. Sandy Blvd . Tel : 503.281.8088

**PHILADFELPHIA**
- 5520 . Whitaker Ave. -Unit 2 . Tel : 215.831.9794
- 571 Adams Ave . Ave.#4 . Tel : 215.342.6623

**TEXAS**
- 1818 E . Pioneer Pkwy. Ste.156 . Tel : 317.461.1461
- 2615 W . Pioneer Pkwy. Ste.136 . Tel : 214.788.2817
- 5302 E . Belknap St.- Ste.D6 . Tel : 817.831.4836
- 3538 W . Walnut St. Tel : 972.272.2253
- 11205 Bellaire Blvd . Tel : 281.561.6600
- 10909 Scarsdale Blvd . Tel : 281.481.2700
- 13480 Veterans Memorial Dr.-Ste. F2. Tel: 281.587.0807

**WASHINTON STATE**
- 766 S.38th St,. Tel : 253.475.2847
- 3818 S.Graham St.-Ste. C Tel : 206.721.2070

Office : 714-590-8740 Fax : 714-590-8776
Cell: 714-603-3509 Toll Free : 1-877-939-0110

## ក្រុមហ៊ុនទទួលផ្ញើប្រាក់ទៅកម្ពុជា

ABC ជាក្រុមហ៊ុនផ្ញើប្រាក់តែមួយគត់នៅស្រុកខ្មែរ ដែលមានការប្រគល់ប្រាក់ដល់ផ្ទះ

- ស្របច្បាប់
- រហ័សទាន់ចិត្ត
- ធានារ៉ាប់រង និងជូនប្រាក់ទៅដល់ផ្ទះ
- កំរៃផ្ញើថោកជាងកន្លែងដទៃ

### ក្រៅពីការផ្ញើប្រាក់ក្រុមហ៊ុនមានលក់

PHONE CARD និង PINLESS សំរាប់ទូរស័ព្ទទៅស្រុកខ្មែរ ដែលផលិតដោយក្រុមហ៊ុន ABC ផ្ទាល់ មានគុណភាពល្អ ហើយជាពិសេស CARD របស់យើងនឹងទុកបានរហូត មិនអស់កំណត់កាលឡើយ ( NEVER EXPIRED) ។

ត្រូវការអ្នកសហការ (AGENTS ) ជាមួយយើងទូទាំងសហរដ្ឋអាមេរិក និងបានទទួលប្រាក់ចំណូលយ៉ាងខ្ពស់ !

ព័ត៌មានបន្ថែមសូមទាក់ទង CHET THACTHER តាមទូរស័ព្ទ និងអាស័យដ្ឋានខាងក្រោម :

ABC MONEY TRANSATION, INC
12019 Garden Grove Blvd., Ste.#204
Garden Grove , CA 92843
chesterthatcher@yahoo.com

តមកទំព័រទី ០១

## ខួបកំណើតនៃ ម៉ាតាំង លូទ័រឃីង...

តែភាពស្មើគ្នានេះ ពុំអាចជ្រួត ជ្រាបឱ្យគ្រប់ទីកន្លែងបានទេ ដោយសារនៅវិទ្យាល័យហ្វីឡាដែលហ្វៀខាងត្បូង សិស្សអាស៊ីប្រមាណ ៥០ នាក់ បានត្រូវរងគ្រោះដោយសារការវាយតបពីក្រុមសិស្សស្បែកខ្មៅច្រើនពួកច្រើនក្រុម បណ្តាលឱ្យរងរបួសប្រមាណ ៣០នាក់ ហើយមាន ៦-៧នាក់ ត្រូវចូលទៅព្យាបាលនៅមន្ទីរពេទ្យជាបន្ទាន់ទៀតផង នាថ្ងៃទី៣ ធ្នូ ដ៏អភ័ព្វនោះ ។

សិស្សអាស៊ីទាំងនោះ ជាទូទៅសម្បុរដោយសាសន៍ចិន បន្ទាប់មកសាសន៍វៀតណាម ដែលក្នុងចំនួននោះ មានអ្នកចេះប្រើភាសាអង់គ្លេសច្បាស់លាស់តិចតួច ។ សិស្សឯទៀតមានខ្មែរ-ឥណ្ឌា-ប៉ាគីស្ថាន... មានចំនួនតិចតួចក៏ទទួលរងគ្រោះដូចគ្នាដែរ ។ កំហឹងក្រេវក្រោធបានផ្ទុះឡើង តែមិនមែនប្រឆាំងនឹងសិស្សអាមេរិកាំងស្បែកខ្មៅដែលកោងកាចនោះទេ តែចំពោះនាយកសាលា ចំពោះនាយកក្រសួងអប់រំ "ស្គូល ឌីស្ទ្រីក" ទៅវិញ ។ សិស្សអាស៊ីចងក្រងគ្នាជាតំណាង គាំទ្រដោយមាតាបិតាដោយចលនាត្រីស្ថានចិន បានផ្តើមបង្ហាញការមិនពេញចិត្តដោយប្រកាសមិនចូលរៀន ទាមទារឱ្យក្រសួងអប់រំរៀបចំសន្តិសុខឱ្យបានគ្រប់គ្រាន់ ឱ្យសិស្សអាស៊ីស្បែកលឿង ។ បាតុកម្មសិស្សប្រមាណ ១០០នាក់ ទៅសម្តែងការទាមទាររបស់ខ្លួននៅក្រសួង "ស្គូល ឌីស្ទ្រីក" នាឱកាសសន្និបាតរបស់ក្រសួងតែម្តង ។ ថ្ងៃទី២០ មករា មិនត្រឹមតែសកម្មភាពបង្ហាញពីការក្រេវក្រោធមិនទាន់ចាប់នៅឡើយតែប៉ុណ្ណោះទេ ពាក្យបណ្តឹងរបស់ក្រុមអ្នកច្បាប់ការពារក្រុមនិស្សិតរងគ្រោះ បានត្រូវដាក់ទៅក្រសួងយុត្តិធម៌ ចោទប្រកាន់ក្រសួង "ស្គូល ឌីស្ទ្រីក" ថាមិនទទួលខុសត្រូវលើតួនាទីរបស់ខ្លួន ទុកឱ្យស្ថានភាពធ្លាក់ដុនដាប រហូតដល់បណ្តាលឱ្យទៅជាគ្រោះថ្នាក់ ។

ថ្ងៃខួប ១៨ មករា របស់ ម៉ាតាំង លូទ័រឃីង បានត្រូវប្រារព្ធយ៉ាងអ៊ឹកធឹកនៅ "វិទ្យាល័យហ្វីឡាដែលហ្វៀខាងត្បូង" រៀបចំដោយ ស្គូល ឌីស្ទ្រីក ចូលរួមដោយអ្នកស្រីប្រធាន អាកម៉ាន់ ដោយពិសេសទៅទៀត ចៅហ្វាយក្រុង ម៉ាយកិល ណាទ័រ និងតំណាងគ្រប់សហគមន៍ចេញមកថ្លែងការណ៍កោតសរសើរពីគុណបំណាច់ និងគុណសម្បត្តិនៃឧត្តមគតិ "ស្រឡាញ់រាប់អានគ្នារវាងប្រជាជនគ្រប់ពណ៌សម្បុរ" របស់លោក ឃីង ហើយដែលឧត្តមគតិនេះ បានត្រូវដាច់រហែកនៅសាលាហ្វីឡាដែលហ្វៀខាងត្បូង ។ ការពិតតំណាងនៃសហគមន៍អាស៊ី មានចាប់អារម្មណ៍លើអំពើហឹង្សានៅវិទ្យាល័យនេះនៅជាច្រើនឆ្នាំមក ហើយ១ក្នុងរយៈពេលមួយឆ្នាំកន្លងទៅ បានធ្វើការព្រមានដល់នាយកសាលា និងនាយកក្រសួងអំពីវិបត្តិដែលបណ្តាលឱ្យសិស្សមិនអាចរៀនសូត្របាន ដោយភាពប្រកាន់ពណ៌សម្បុរ តែពុំមានវិធានការណ៍ណាមួយដែលចាត់តាំងដើម្បីទប់ស្កាត់អំពើហឹង្សាទាំងនោះសោះ ។

នាថ្ងៃខួបកំណើតលោក ឃីង នៅវិទ្យាល័យហ្វីឡាដែលហ្វៀខាងត្បូងឆ្នាំនេះ អត្ថន័យនៃសុន្ទរកថាជាទូទៅ ហាក់ដូចជាសម្តែងរកការជានាគ្នារវាងក្រុមសិស្សស្បែកខ្មៅ និងសិស្សស្បែកលឿង មិនដូចឆ្នាំមុនៗ ដែលគេថ្លែងសំរាប់ស្បែកស និងស្បែកខ្មៅនោះទេ ។ ថ្ងៃនេះមនុស្សម្នាប្រមាណ ១៥០នាក់ដែរ អ្នកយកពត៌មានជាច្រើនរង់ចាំព្រឹត្តិការណ៍ចម្លែក តែសហគមន៍ចិន យួន មិនបានមកទេ លើកលែងតែតំណាងបីបួននាក់ ហើយនឹងតំណាងសហគមន៍ខ្មែរមានព្រះតេជគុណចៅអធិការវត្តព្រះពុទ្ធរង្សី វដ្តមុនី. នាយកប្រតិបត្តិសមាគម វ៉ង ស៊ន តែប៉ុណ្ណោះ ។



ព្រះអង្គព្រះចៅអធិការ វដ្តមុនី



នាយិកាសហគមន៍ខ្មែរ វ៉ង ស៊ន


ជិន វុត្ថា ទំនាក់ទំនងសាធារណៈសាលាក្រុង

ជិន វុត្ថា អតីតនាយកសមាគម និងជាបុគ្គលិកសាលាក្រុងខាងផ្នែកធនធានមនុស្ស បាននិយាយប្រាប់ខ្មែរប៉ុស្តិ៍ថា "ថ្ងៃនេះគេប្រារព្ធខួបកំណើតលោក ឃីង នៅសាលាហ្វីឡាដែលហ្វៀខាងត្បូងនេះ ដោយគេចង់បង្ហាញថា គេយកឧត្តមគតិលោក ឃីង ដែលជាវិរៈបុរសខាងសិទ្ធិមនុស្ស មកធ្វើឱ្យមានការជានាគ្នាវិញ រវាងក្រុមសិស្សស្បែកខ្មៅ និងក្រុមសិស្សអាស៊ី ឱ្យដូចគ្រួសារតែមួយ គឺត្រូវមានការគោរពគ្នាទៅវិញទៅមក ទៅតាមភាពទស្សនៈជាមនុស្សពុំមានពណ៌ស្បែកនៃមនុស្សទេ" នៅលើសំនួរថា តើព្រឹត្តិការណ៍នៃថ្ងៃទី៣ ខែធ្នូមុននោះ អាចផ្តល់ជាលទ្ធផលល្អដល់សហគមន៍អាស៊ី នៅសាលារៀនទេ ពីព្រោះនេះ ពុំមែនជាព្រឹត្តិការណ៍ថ្មីទេ លោក ជិន វុត្ថា ឆ្លើយថា " អាចមានចម្លើយពីរ ទៅតាមទស្សនៈនៃអ្នកឆ្លើយ ម្យ៉ាងគេថា លោក ម៉ាតាំង លូទ័រឃីង មុខជានាំមកនូវការផ្សះផ្សាគ្នាបានជាប្រាកដ តែទស្សនៈម្យ៉ាងទៀតនិយាយថា ការរៀបចំយកថ្ងៃនេះមកប្រើ គឺគ្រាន់តែជាឆាកល្ខោនតែប៉ុណ្ណោះ ពីព្រោះ

(តទៅទំព័រទី ១៧)

FOR SALE BY OWNER

HASS'S AUTO COLLISION & BODY SHOP
615 W. Fisher Avenue. Philadelphia, Pa 191203




HASS'S AUTO ជួសជុលតួឡានដែលបុគ្គាម្ចាស់ហាងចូលនិវត្តន៍
-ហាងមានដំណើរការ១៧ឆ្នាំមកហើយ-ពាណិជ្ជកម្មមានលំនឹងល្អគ្រប់រដូវ
លោកអ្នកអាចទិញតែពាណិជ្ជកម្មក៏បាន
-ទិញដីជាមួយនឹងផ្ទះក៏បាន-ទិញទាំងពីររួមគ្នាក៏បាន
បើចង់ដឹងច្បាស់សូមទូរស័ព្ទរកឈ្មោះ "នីក"

**267-242-7938**

Owner is retiring. 17 years in business at this location.
Well established business, all seasons are busy.
Option to buy only business, real estate, or both.

For more information,
please contact Nick at 267-242-7938

DRANOFF ASSOCIATES
*Attorneys at Law*



"ដ្រាណុហ្វ អាសូស៊ីយេត (DRANOFF ASSOCIATE ) គឺជាមណ្ឌលការពារតាមផ្លូវច្បាប់ ដែលធ្វើការប្រកបដោយភក្តីភាព ដើម្បីតំណាងឱ្យអ្នករងគ្រោះដែលមានរបួសរាងកាយ ។

ស្ទីវិន ដ្រាណុហ្វ (STEVEN DRANOFF) គឺជាមេធាវីនៅសាលាក្តីមានបទពិសោធន៍៣៥ឆ្នាំ ធ្វើជាតំណាងឱ្យឯកជន ដែលពុំមែនឱ្យក្រុមហ៊ុន ឬក្រុមធានារ៉ាប់រងទេ ។

យើងធានាថា ផ្តល់គុណភាពសេវាច្បាប់យ៉ាងខ្ពស់ ហើយយកចិត្តទុកដាក់ ជាពិសេសដល់អតិថិជនរបស់យើង ។

យើងធ្វើការដោយយកកំរៃពីការងារដែលប្រគល់ឱ្យ - បានន័យថា លោកអ្នកមិនចាំបាច់ចេញថ្លៃចំណាយអ្វី មុននឹងលោកអ្នកទទួលប្រាក់សងពីមុខរបួសលោកអ្នកនោះទេ ។

ជំនួយខាងផ្លូវច្បាប់អាចផ្តល់ជូនជាភាសា ស្បានីស ខ្មែរ វៀតណាម កូរ៉េ និង ចិន ។

សូមអញ្ជើញទូរស័ព្ទមកពេលនេះភ្លាមចុះ ដើម្បីពិគ្រោះសម្ងាត់ដោយមិនគិតថ្លៃ ឬក៏អញ្ជើញមកជួបនៅការិយាល័យយើងក៏បាន ។

DRANOFF ASSOCIATES
121 South Broad Street, Suit 1210, Philadelphia, PA 19107
215-732-3333 (phone) 215-732-8059 (fax)
sdranoff@dranofflaw.com

# Computers for Chilfren
## Help Care for Cambodia´s Fuhture

Join us in our venture to improve the quality of education by establishing an eco-friendly computer lab at the Russey Chroy School in rural Cambodia. The impact of a single computer will enlighten the life of a community. Help us expand the knowledge to those who need it the most.

**Where**
Edmund D. Bossone Research Enterprise Center
Drexel University
31st and Market Street
Philadelphia, PA 19104

**Program**
Cocktails & Hor d' oeurvres at 7PM
Cambodian Dance Performances at 8PM

**Date**
Saturday, February 27, 2010

**Tickets**
$45

**RSVP**
To Noreen Neal at Noreen914@gmail.com
or through cambodianecolab.com

For more information about this project, please visit www.cambodianecolab.com

FOUNDATION



CHAMPIONS OF CARING

Organization Sponsors: Chi Upsilon Sigma National Latin Sorority Inc. (Drexel), Cambodian Education Excellence Foundation, and Champions of Caring


Nationwide

# Nationwide

Insurance & Financial Service
សេវាធានារ៉ាប់រង និងហិរញ្ញវត្ថុ
We offer Cheap Price for Every Client
យើងធ្វើជូនគ្រប់ភ្ញៀវដោយតម្លៃទាប

| | |
|---|---|
| Business Liability Insurance | ធានារ៉ាប់រងជំនួញឃោរកម្ម |
| Home Insurance | ធានារ៉ាប់រងផ្ទះសម្បែង |
| Health Insurance | ធានារ៉ាប់រងសុខភាព |
| Auto Insurance | ធានារ៉ាប់រងរថយន្ត |
| Life Insurance | ធានារ៉ាប់រងជីវិត |

Discount 30% when you purchase Home & Auto Insurance
ចុះតម្លៃ ៣០ % បន្ថែមបើលោកអ្នកទិញ ធានារ៉ាប់រងផ្ទះ និងរថយន្តរួមគ្នា

South Philadelphia office:
600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

North Philadelphia office:
6603 Bustleton Ave.
Philadelphia, Pa 19149
Tel: (215) 335-2140
Fax: (215) 335-2147


CAMBODIAN ASSOCIATION - PROGRAMS & EVENTS ANNOUNCEMENT · JANUARY 2010

# KHMER LANGUAGE & CULTURE PROGRAM

*The Cambodian Association of Greater Philadelphia is pleased to announce our Khmer Language and Culture Dance Program. Partially funded by Philadelphia Cultural Fund, this program offers Khmer language classes and cultural performing arts lessons to children and youth from 5 and up.*



ក ខ គ ឃ ង
ច ឆ ជ ឈ ញ
ដ ឋ ឌ ឍ ណ
ត ថ ទ ធ ន
ប ផ ព ភ ម
យ រ ល វ ស
ហ ឡ អ ។



*These classes are held every **Sunday at 10:30am** at our North Office at 5412 North 5th Street, Philadelphia, PA 19120. Register your child by calling Ms. Putery Long at (215) 324-4070. One time registration fee is $20 to cover books and other supplies.*

*Khmer class is taught by Certified teacher, Chantha Chum, from the School District of Philadelphia, who is passionate to preserve Khmer language and culture.*

សមាគមខ្មែរប្រចាំតំបន់ហ្វីឡាដែលហ្វៀមានសេចក្ដីរីករាយសូមជូនដំណឹងអំពីកម្មវិធីសិក្សាអក្សរសាស្ត្រ វប្បធម៌ខ្មែរ និងរបាំប្រពៃណីខ្មែរដល់សិស្សានុសិស្សនិងយុវជន។

កម្មវិធីទាំងពីរនេះនឹងបើកបង្រៀនរៀងរាល់ថ្ងៃអាទិត្យ វេលាម៉ោង ១០:៣០ព្រឹក នៅការិយាល័យខាងជើង លេខ ៥៤១២ ផ្លូវលេខ ៥។

បើលោកអ្នកមានសំណួរអ្វី ឬ ចង់ចុះឈ្មោះអោយកូនចៅលោកអ្នកចូលកម្មវិធីនេះ សូមអញ្ជើញទូរស័ព្ទមកយើងខ្ញុំតាមលេខ ២១៥-៣២៤-៤០៧០។ តំលៃចុះ ២០ ដុល្លារសំរាប់សៀវភៅសិក្សា។

តមកទំព័រទី ០១

## ខ្មែរជួយរំដោះទុក្ខប្រជាជន...

ចំណតយន្តហោះត្រូវខូចខាតពុំអាចប្រើការ បានក៏យន្តហោះជំនួយ បានទៅចុះចតប្រទេសជិតខាង ដែល នៅមិនឆ្ងាយពី "ព័រអូប្រាំង" ដែលជារដ្ឋធានីនៃ



វិមានប្រធានាធិបតីដែលរងការខូចខាតដោយការរញ្ជួយដី

ហៃទី ហើយនាំជំនួយចូលតាមរថយន្ត ឬតាមឧទ្ធម្ភាក-ចក្រ ឬទម្លាក់ពីលើយន្តហោះតាមឆ័ត្រយោង ។ ម្ហូបអាហារ ថ្នាំពេទ្យ គ្រឿងបរិក្ខាចាំបាច់ បានចូលទៅដល់ពលរដ្ឋជាបន្តបន្ទាប់ ការរុករកមនុស្សដែលសង្ស័យថា នៅរស់រានមាន ជីវិតនៅក្រោមគំនរថ្ម ឬស៊ីម៉ងត៍ បានត្រូវបញ្ឈប់នេ ៅថ្ងៃអាទិត្យ ទី២៤ នេះហើយដែរ ដោយក្ដីសង្ឃឹមថា មានមនុស្សនៅរស់នៅឡើយនោះគ្មានទៀតទេ ។

ប្រទេសហៃទី ជាប្រជុំកោះ នៅមិនឆ្ងាយពី គុបា មានប្រជាពលរដ្ឋ ១០លាននាក់ ជាប្រទេសក្នុងចំណោមប្រទេសក្រជាងគេ ទី១៤៩ ក្នុងចំណោមប្រទេស ១៨៩ ។ ដឹកនាំមុនគេដោយប្រធានាធិបតីស្បែកខ្មៅ នៃសាធារណរដ្ឋហៃទី តាំងពីដើមសតវត្សទី១៩ បន្ទាប់មកដោយរបបផ្ដាច់ការនិយមបន្តបន្ទាប់គ្នា រាប់ទាំងអំពើហឹង្សានយោបាយ រហូតដល់ឆ្នាំ ១៩៩០ ទៅប្រធានាធិបតី អារីស្ទីត យកអំណាចដាក់ជារបបប្រជាធិបតេយ្យបាន តែមិនយូរប៉ុន្មានក៏ត្រូវពួកយោធាធ្វើរដ្ឋប្រហារទម្លាក់ពីអំណាចបានបួនឆ្នាំ ។ ឆ្នាំ១៩៩៤ សហរដ្ឋអាមេរិក បានបញ្ជូនទ័ពទៅរៀបរយឱ្យគោរពរដ្ឋធម្មនុញ្ញវិញ ជាមួយនឹងការត្រឡប់របស់ អារីស្ទីក មកកាន់អំណាចប្រទេសវិញ ។ ប្រធានាធិបតីចុងក្រោយបង្អស់ ដែលផែនដីរញ្ជួយយកផ្ទះ និងវិមានរបស់លោកជាគំនរផេះអស់រលីង លោកឈ្មោះ រីណេ ប្រេវ៉ាល់ ។

សហគមន៍ខ្មែរ នៅហ្វីឡាដែលហ្វៀ បានផ្ដើមបង្ហាញសប្បុរសធម៌ដំបូងគេ ជាគំនរភារទឹកទៅដល់នាឱកាសដែលពួកខ្លួនរងគ្រោះដូចគ្នា នាអំឡុងឆ្នាំ ១៩៨០ ។ ថ្វីត្បិតតែជីវភាពនៅយ៉ាបឃីននារដ្ឋដ៏ក្រីក្រនេះ ពួកគាត់ប្រមូលប្រាក់ភ្លាមៗ ផ្ញើជំនួយមនុស្សធម៌តាមរយៈគ្រូពេទ្យគ្មានព្រំដែន ចំនួន ១២៤៦ ដុល្លារ ៕

***ខ្មែរប៉ុស្តិ៍***

## Port-au-Prince's Death Toll Confirmed 150,000; No Longer Rescuing



THE KHMER POST
Dannaly Sam

••The death toll of Port-au-Prince, Haiti has been confirmed to be 150, 000 by Haiti's information minister this past Sunday since the earthquake first hit, acknowledging there are many more who have been either not yet discovered beneath the rubbles or have died in other parts of the country.

"Nobody knows how many bodies buried in the rubble 200,000, 300,000?" the information minister Marie-Laurence Jocelyn Lassegue said. "Who knows the overall death toll?" (Associated Press)

Marie-Laurence Jocelyn Lassegue told The Associated Press that the estimation for the death toll was based upon a body count in Port-au-Prince by a state company named CNE who collected corpses and buried them in a mass grave. The death toll also does not include other areas that were affected, nor does it include familial burials.

The United Nations also declared on Saturday that the Haitian government has decided the phase of searching and rescuing of civilians to be over.

The government will now focus on caring for the thousands of survivors where many are without proper supplies of food, water, shelter, and medicine.

The flow of supplies to survivors has improved in Robert Gates' opinion, the U.S. Defense Secretary, since the first week of the 7.0 magnitude earthquake took place on January 12, 2010.

"Supplies are beginning to get out to the people," Gates said.

In an effort to lend additional foreign aid that has been streaming from all parts of the world, the U.S. will deploy American soldiers from Fort Knox to Haiti to help assist with relief efforts for the surviving thousands.

BBC News Images

A young girl sits on her bed writing.

AFP-US Marines from the 22nd Marine Expeditionary Unit ussnload water.

AP-A young girl walks past a sign welcoming U.S. Marines and also stating there are dead bodies in the destroyed building.





HONG KONG
SUPERMARKET
FAMER´S BEST
$1.69/can
$3.49 each
Newly Renovated.
Added new section .
Clean and Improved
management !
ទើបនឹងកែលំអរថ្មីឡើងវិញ
-បន្ថែមផ្នែកលក់ថ្មីទៀត
ហាងស្អាត ហើយបង្កើន
គុណភាពគ្រប់គ្រង
Weekly Sale
លក់ចុះថ្លៃរៀងរាល់សប្តាហ៍
$2.99/bag
$7.99
$2.99
$6.99/box
$1.29/can
$2.49/28oz
$2.49/bag
2 for $3
$4.99 / lb
OPEN
7 DAY
8:00-9:00
571 ADAMS AVE.PHILADELPHIA,PA19120
Tel: 215-7281300 Fax: 215-728-1600
• ចំណាយ $140ដុល្លារ ទទួលបានអង្ករស្រូវស ២៥ ផោន
• ចំណាយ $100ដុល្លារ ទទួលបានទូកែសជ្ជៈ ឬទឹកញ្ជប់មួយប្រអប់(តម្លៃ 8.99)
• ចំណាយ $25 ដុល្លារទទួលបានទឹកសណ្តែកមួយដប ឬទឹកត្រីមួយដប ។

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឲ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី២២ ខែមករា ឆ្នាំ២០១០

# UN Notes Progress and Problems in Schools

By Abby Seiff
THE CAMBODIA DAILY

Education in Cambodia is improving, with the number of children enrolled in primary school up, the number of dropouts down and the gender gap shrinking. But the country still places among the lowest in the world, according to the results of a global education index released yesterday.

Among 129 countries, Cambodia was ranked 104 on Unesco's Education Development Index—which calculates a ratio between a low of 0 and a high score of 1 based on factors such as adult literacy, primary school enrolment, gender disparities and quality of education.

The ranking is the same as last year's, and regionally puts Cambodia above only Laos, but Cambodia's ratio score itself did rise by 0.4 to 0.781.

The findings are mixed. The report singles out a Cambodian scholarship scheme to provide conditional grants to the families of poor students, particularly females and minorities, as having a marked impact on enrolment. "Cambodia demonstrated that financial incentives could both raise the demand for primary schooling and increase the likelihood of girls entering lower secondary school," noted the study.

But if Cambodia is improving, it is doing so from a bleak baseline. For every 100 students that enter primary school, 60 leave before graduating. And while the global maximum for student-to-teacher ratio is set at 40 students to a teacher, Cambodia's is 55 to one. "The government is trying its best to improve" the ratio, said Ministry of Education secretary of state, Mak Vann, who admitted there were a number of obstacles facing education. "Teacher training is one of the things we need to improve in order to raise the quality of education."

Rong Chhun, president of the Cambodian Independent Teacher Association, said he was not surprised by the findings and fingered poor pay as the root of the problem. "The government must increase the number of teachers in the countryside and their salary, so they don't have to take on two jobs. If they have two jobs, it affects the quality of education," he said. "If we have a poor education system, the country can't develop."

*(Additional reporting by Khuon Narim)*

# អង្គការសហប្រជាជាតិកត់សម្គាល់ឃើញ ការវិវឌ្ឍនិងបញ្ហានៅតាមសាលារៀន

ដោយ Abby Seiff
THE CAMBODIA DAILY

យោងតាមលទ្ធផលនៃសន្ទស្សន៍ផ្នែកអប់រំទូទាំងពិភពលោក ដែលបានចេញផ្សាយកាលពីម្សិលមិញបានឲ្យដឹងថា វិស័យអប់រំនៅក្នុងប្រទេសកម្ពុជាកំពុងតែប្រសើរឡើង ដោយចំនួនកុមារដែលបានចុះឈ្មោះចូលរៀនសាលាបឋមសិក្សាកើនឡើង ចំនួនសិស្សដែលបោះបង់ចោលការសិក្សាធ្លាក់ចុះ ហើយគម្លាតយេនឌ័រកាន់តែតូច ។ ប៉ុន្តែប្រទេសកម្ពុជានៅតែស្ថិតក្នុងចំណោមប្រទេសដែលមានចំណាត់ថ្នាក់ទាបបំផុតនៅក្នុងពិភពលោក ។

ក្នុងចំណោមប្រទេសចំនួន១២៩ ប្រទេសកម្ពុជាស្ថិតក្នុងចំណាត់ថ្នាក់ទី១០៤នៅក្នុងសន្ទស្សន៍អភិវឌ្ឍន៍វិស័យអប់រំរបស់អង្គការយូណេស្កូ ដែលគណនាអត្រាពិន្ទុ០ និងពិន្ទុខ្ពស់១ ដោយផ្អែកលើកត្តានានាដូចជាការចេះអាននិងចេះសរសេររបស់មនុស្សពេញវ័យ ការចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សា ភាពខុសគ្នារវាងយេនឌ័រនិងគុណភាពអប់រំ ។

ចំណាត់ថ្នាក់នេះគឺដូចគ្នានឹងចំណាត់ថ្នាក់កាលពីឆ្នាំមុន ហើយបើធៀបនៅក្នុងតំបន់ ប្រទេសកម្ពុជាស្ថិតនៅលើតែប្រទេសឡាវប៉ុណ្ណោះ ប៉ុន្តែអត្រាពិន្ទុរបស់កម្ពុជាបានឡើងពី០,៤ ទៅ០,៧៨១ ។

លទ្ធផលគឺលាយឡំគ្នា ។ របាយការណ៍នេះចង្អុលបង្ហាញថា គម្រោងអាហារូបករណ៍កម្ពុជាមួយដែលផ្ដល់ជំនួយឥតសំណងតែមានលក្ខខណ្ឌដល់គ្រួសារសិស្សក្រីក្រ ជាពិសេសសិស្សស្រីនិងជនជាតិភាគតិចនោះ មានផលប៉ះពាល់ដ៏គួរឲ្យកត់សម្គាល់លើការចុះឈ្មោះចូលរៀន ។

ការសិក្សាបានកត់សម្គាល់ឃើញថា "ប្រទេសកម្ពុជាបានបង្ហាញថា ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុអាចបង្កើនតម្រូវការនៃការចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាផងនិងបង្កើនឱកាសចូលរៀនសាលាមធ្យមសិក្សាកម្រិតទាបរបស់សិស្សស្រីផង" ។

ប៉ុន្តែប្រសិនបើប្រទេសកម្ពុជាកំពុងតែប្រសើរឡើងមែន វាប្រសើរឡើងក្នុងកម្រិតវាស់វែងមិនសូវល្អទេ ។ សម្រាប់រាល់សិស្ស១០០នាក់ដែលចូលរៀនសាលាបឋមសិក្សា មាន៦០នាក់បានឈប់រៀនមុនពេលបញ្ចប់ ។ ហើយខណៈដែលចំនួនសិស្សអតិបរមាធៀបនឹងគ្រូទូទាំងពិភពលោកកំណត់ត្រឹមសិស្ស៤០នាក់ក្នុងគ្រូម្នាក់ ប្រទេសកម្ពុជាមានសិស្ស៥៥នាក់ក្នុងគ្រូម្នាក់ ។

លោក ម៉ក់ វ៉ាន់ រដ្ឋលេខាធិការក្រសួងអប់រំដែលបានទទួលស្គាល់ថា មានឧបសគ្គមួយចំនួនដែលវិស័យអប់រំកំពុងប្រឈមនោះបានមានប្រសាសន៍ថា "រដ្ឋាភិបាលកំពុងប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីធ្វើឲ្យអត្រាធៀបនេះប្រសើរឡើង ។ ការបណ្ដុះបណ្ដាលគ្រូបង្រៀនគឺជាបញ្ហាមួយក្នុងចំណោមបញ្ហានានាដែលចាំបាច់ត្រូវកែលំអដើម្បីបង្កើនគុណភាពអប់រំ" ។

លោក រ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យបានមានប្រសាសន៍កាលពីម្សិលមិញថា លោកមិនភ្ញាក់ផ្អើលនឹងលទ្ធផលទាំងនេះទេ ហើយបានចង្អុលបង្ហាញថា ប្រាក់ខែមិនគ្រប់គ្រាន់គឺជាមូលហេតុនៃបញ្ហា ។

លោកបានមានប្រសាសន៍ថា "រដ្ឋាភិបាលត្រូវតែបង្កើនចំនួនគ្រូបង្រៀននៅតាមជនបទ និងដំឡើងប្រាក់ខែរបស់ពួកគេ ដូច្នេះពួកគេនឹងមិនចាំបាច់ធ្វើការងារពីរកន្លែងទេ ។ ប្រសិនបើពួកគេមានការងារពីរកន្លែង វាប៉ះពាល់ដល់គុណភាពនៃការអប់រំ ។ ប្រសិនបើប្រព័ន្ធអប់រំយើងមិនល្អ ប្រទេសជាតិមិនអាចអភិវឌ្ឍបានឡើយ" ។E *(របាយការណ៍បន្ថែមដោយ ឃួន ណារីម)*

ការិយាល័យថែទាំសុខភាពគ្រួសារ

5746 Rising Sun Avenue. Philadelphia, Pa 19120
Phone: (215)904-6891 Fax: (215) 745-2290

DR. TRUONG H. NGUYEN, M.S., D.O., P.C

FAMILY MEDICINE – INTERNAL MEDICINE – OSTEOPATHIC MANIPULATIVE THERAPY

វេជ្ជបណ្ឌិតជំនាញខាងព្យាបាលជម្ងឺទឹកនោមផ្អែម_សរសៃបេះដូង_ពិនិត្យសុខភាពស្ត្រី (GYN)
_ពិនិត្យតម្រងនោម_ប្រព័ន្ធរំលាយអាហារ...

* ផ្នែកពិនិត្យសុខភាពជាប្រចាំ និងព្យាបាលជម្ងឺស្បែក....ឈឺក្បាលប្រកាំង, ឈឺសន្លាក់ដៃជើង
បញ្ជាក់សុខភាពសម្រាប់អាពាហ៍ពិពាហ៍, សម្រាប់ធ្វើដំណើរ និង សម្រាប់សាលារៀន
* **ជាពិសេស : ទទួលព្យាបាលអ្នកគ្រោះថ្នាក់មានមុខរបួស ឬរអិលដួលនៅកន្លែងធ្វើការ**
**យើងណែនាំផ្ដល់មេធាវីដែលមានបទពិសោធន៍ជាង ២០ ឆ្នាំ និងអ្នកបកប្រែភាសាជំនាញ មានខ្មែរ-ចិន-វៀតណាម**
**ជូនដោយឥតគិតថ្លៃ បើលោកអ្នកត្រូវការ :**
* ធានាថា យើងធ្វើការបានលទ្ធផលឆាប់រហ័ស-លើសពីនេះ យើងរីករាយនឹងជួយដល់ភ្ញៀវណាដែល
មិនចេះនិយាយអង់គ្លេស ហើយចង់កំណត់ពេលទៅមន្ទីរពេទ្យ ឬចង់ប្តូរ
ក្រុមហ៊ុនធានាសុខភាព (Health Insurance)
* **យើងទទួល មេឌីកេដ,មេឌីឃែ , និង អ៊ិនសួរិន ស្ទើរតែទាំងអស់**
**និងគិតតម្លៃទាបជូនអ្នកដែលមិនមាន អ៊ិនសួរិន ទៀតផង ។**

**ការិយាល័យបើកទ្វារ :៣**
ថ្ងៃ ច័ន្ទ -អង្គារ-ពុធ- និង សុក្រ
ពីម៉ោង ៩ព្រឹកដល់១រសៀល
និងពីម៉ោង ៣ ដល់ ៧ ល្ងាច
**បិទទ្វារ :** ថ្ងៃ សៅរ៍ និងថ្ងៃអាទិត្យ និងព្រហស្បតិ៍

# ទស្សនៈ វិស័យ: ថ្ងៃ៧មករាជាថ្ងៃជោគជ័យក្រុមបំរើយួនវៀតណាម



**ដោយ : ម៉ម យ៉ឹន**

...បណ្ដាជនជាតិខ្មែរ ដែលបានសិក្សារៀនសូត្រ ហើយមានចំណេះដឹងច្បាស់លាស់ទៅតាមគតិបណ្ឌិត បានដឹង និងយល់ច្បាស់លាស់ពីហេតុការណ៍សំខាន់ៗទាំងអស់ ដែលបានកើតមានឡើងនៅលើប្រទេស និងប្រជាជាតិខ្មែរ តាំងពីបូរាណកាល រហូតមកដល់បច្ចុប្បន្នកាលនេះ ។

មនុស្សណាក៏ដោយ ដែលសន្មតថា ជាអ្នកចេះដឹង ហើយបានក្លាយជានាម៉ឺនសព្វមុខមន្ត្រី ជាអ្នកដឹកនាំកិច្ចការប្រទេសជាតិ ទោះបីក្នុងឋានៈជាប្រមុខរដ្ឋក្ដី ជានាយករដ្ឋមន្ត្រីក្ដី ជាមន្ត្រីគ្រប់លំដាប់ថ្នាក់ក្ដី សុទ្ធតែតម្រូវឱ្យមានចំណេះវិជ្ជាក្នុងកំរិតមួយដ៏ខ្ពង់ខ្ពស់ទៅតាមតំណែងដែលត្រូវទទួល ។

ផ្ទុយទៅវិញ បើសិនណាជាមន្ត្រីនៅក្នុងលំដាប់ថ្នាក់ណាមួយ ជាមនុស្សគ្មានចំណេះវិជ្ជា និងសមត្ថភាពគ្រប់គ្រាន់ ហើយបានក្លាយទៅជាអ្នកកាន់តំណែងជាមន្ត្រីសំខាន់ បុគ្គលនោះ ប្រាកដជាពុំអាចពុំអាចបំពេញមុខនាទីនោះបានលទ្ធផលល្អប្រសើរទៅបានទេ ហើយថែមទាំងបណ្ដាលឱ្យមានគ្រោះថ្នាក់មហន្តរាយទៅដល់បណ្ដាជនដទៃ និងប្រទេសជាតិទៀតផង ។

មានគ្រួសារខ្លះ មានឪពុកម្ដាយជាមនុស្សបានសិក្សារៀនសូត្រ ហើយមានចំណេះវិជ្ជាល្មម អាចចាត់ទុកថា ជាបញ្ញវ័ន្តបានដែរ ផ្ទុយទៅវិញ ឪពុកម្ដាយនេះ ពុំមានចរិយាសម្បត្តិ គុណសម្បត្តិ ជាមនុស្សប្រកបដោយគុណធម៌ សីលធម៌ និងគតិយុត្តិធម៌ទេ ត្រឡប់ទៅជាយកចំណេះវិជ្ជារបស់ខ្លួននោះ ទៅធ្វើជាឧបករណ៍មួយ សំរាប់ស្វែងរកតែផលប្រយោជន៍ផ្ទាល់ខ្លួន ដោយអំពើទុច្ចរិត លោភលន់ និងសង្កត់សង្កិតទៅលើបណ្ដាជនដទៃទៅវិញ រហូតបណ្ដុះបណ្ដាលកូនប្រុសស្រីឱ្យក្លាយទៅជាក្មេងខ្វះគុណធម៌ សីលធម៌ព្រហើនកោងកាច ដោយអាងទៅលើអំណាច ទ្រព្យសម្បត្តិ មាសពេជ្រ លុយកាក់មហាសាលរបស់ឪពុកម្ដាយខ្លួននោះ នេះក៏ជាឧទាហរណ៍មួយដែរ ។

ដោយសារតែមានមនុស្ស មានលក្ខណៈសម្បត្តិដូចបានរៀបរាប់ខាងលើ ហើយបានក្លាយទៅជាអ្នកដឹកនាំប្រទេសជាតិថែមទៀតផង ទើបប្រទេស និងប្រជាជាតិនោះ ប្រាកដជាត្រូវធ្លាក់ទៅក្នុងមហាគ្រោះថ្នាក់មហន្តរាយពុំអាចគេចរួចឡើយ ។

ដើម្បីជៀសវាងឱ្យបានចេញរួចផុតពីមហាគ្រោះថ្នាក់មហន្តរាយដោយសារមេដឹកនាំរបបនេះ ទើបបានជានៅក្នុងប្រទេសស្ទើរតែទាំងអស់រមែងតែងតែបង្កើននូវក្បួនខ្នាត ច្បាប់បញ្ញត្តិ ដើម្បីដកហូតតំណែងមេដឹកនាំខ្វះសមត្ថភាព មិនត្រូវទុកបណ្ដោយឱ្យដឹកនាំប្រទេសជាតិដ៏យូរអង្វែងទៅបានទេ ។

វិធានការណ៍ ដើម្បីដកហូត ដែលប្រកបដោយសន្តិវិធី និងយុត្តិធម៌ ជៀងវាងការជ្រួលច្របល់បង្កើតទៅជាសង្គ្រាមបង្ហូរឈាម ត្រូវតែអនុវត្តទៅតាមលទ្ធិប្រជាធិបតេយ្យ គឺការបោះឆ្នោតចេញមកពីប្រជាពលរដ្ឋទូទាំងប្រទេស ធ្វើជាអ្នកជ្រើសរើសទៅតាមនិតិវិធី ដែលបានរៀបចំការបោះឆ្នោតដោយយុត្តិធម៌ ទៅតាមនិតិរដ្ឋដែលបានចែងអំពីសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងជ្រើសរើសមេដឹកនាំប្រទេសជាតិ ។

នៅក្នុងប្រទេសណា ដែលមានមេដឹកនាំគ្មានសមត្ថភាព រួចហើយមានអគតិទាំង ៤ គឺ :

១- ឆន្ទាគតិ ជាគតិលំអៀង ដោយសេចក្ដីស្រឡាញ់

២- ទោសាគតិ ជាគតិលំអៀង ដោយសេចក្ដីស្អប់

៣- មោហាគតិ ជាគតិលំអៀង ដោយសេចក្ដីល្ងង់ខ្លៅ

៤- លោភាគតិ ជាគតិលំអៀង ដោយសេចក្ដីចង់មានចង់បានពុំចេះស្កប់ស្កល់ ។ ប្រទេសនោះ ប្រាកដជាត្រូវកើតមានបញ្ហាវិបត្តិយ៉ាងធ្ងន់ធ្ងរ រហូតបណ្ដាលនាំឱ្យឈានទៅដល់គ្រោះថ្នាក់មហន្តរាយថែមទៀតផង ។

មេដឹកនាំដ៏គ្មានសមត្ថភាព មានន័យថា ជាមេដឹកនាំខ្វះនូវលក្ខណៈជាគុណសម្បត្តិសំខាន់ៗដែលជាគតិបណ្ឌិតពិតប្រាកដ ក្នុងឋានៈជាមេដឹកនាំដ៏ល្អត្រឹមត្រូវ ពេញលេញជាមេដឹកនាំ ។

បុគ្គលិកលក្ខណៈជាគុណសម្បត្តិដែលមេដឹកនាំត្រូវមានគឺ :

១- ត្រូវមានចំណេះវិជ្ជាទូទៅគ្រប់គ្រាន់ ដែលមនុស្សម្នាក់ ត្រូវតែបានចូលទៅសិក្សារៀនសូត្រនៅក្នុងសាលារៀន រហូតបានចប់ការសិក្សាប្រកបដោយភាពជោគជ័យទៅតាមលក្ខណៈច្បាប់ ។

២- ត្រូវបានបំពេញមុខនាទីសំខាន់ៗ ជាគុណប្រយោជន៍ដល់ប្រទេសជាតិ មាតុភូមិ ក្នុងឋានៈជាមន្ត្រីដ៏មានឧត្តមគតិ មនសិការស្នេហាជាតិ មាតុភូមិដោយប្តូរផ្តាច់ពិតប្រាកដ ជាមន្ត្រីមានគុណធម៌ សីលធម៌ ចរិយាធម៌ សច្ចធម៌ យុត្តិធម៌ ដែលជាលក្ខណៈសម្បត្តិតម្រូវឱ្យមន្ត្រីនោះ ក្លាយទៅជាមេដឹកនាំពិតប្រាកបាន ។

៣- ត្រូវមានសុខភាព និងកាយសម្បទាល្អបរិបូរ ដែលបង្ហាញពីភាពរឹងមាំខាងឆន្ទៈអង់អាចក្លាហាន ដែលដុះចេញមកពីសតិបញ្ញា សតិសម្បជញ្ញៈ វិចារណញ្ញាណ មានសុទិដ្ឋិនិយមជាសម្មាទិដ្ឋក្នុងការដឹកនាំប្រទេស និងប្រជាជាតិឱ្យបានទៅដល់គោលដៅជាជ័យជំនះពិតប្រាកដ មានន័យថា សុខភាពខាងខួរក្បាល ( ប្រាជ្ញា) និងបេះដូង (ចិត្ត) ដែលជាអវយវៈសំខាន់បំផុតនៅក្នុងរាងកាយរបស់មនុស្ស ។

បើកាលណាមនុស្សមានខួរក្បាល និងបេះដូងប្រាសចាកពីលក្ខណៈសម្បត្តិជាគុណធម៌ហើយ មនុស្សនោះអាចចាត់ទុកជាមនុស្សពុំមានលក្ខណៈសម្បត្តិពេញបរិបូរទេ ប្រៀបដូចជាមនុស្សខូចសតិ វិកលចរិត មានទុទិដ្ឋិនិយមជាមិច្ឆាទិដ្ឋិយល់ខុសជាត្រូវយល់ខ្មៅជាស យល់អាក្រក់ជាល្អ រហូរដល់មានអំនួតអួតអាង យល់ថាមានតែខ្លួនឯងម្នាក់ទេ ដែលជាមនុស្សល្អវិសេសជាគេបង្អស់ ។

៤- ត្រូវមានគតិបណ្ឌិត ៣ ប្រការ គឺ :

ក- ឃើញទ្រព្យសម្បត្តិ មាសពេជ្រ លុយកាក់របស់ជនដទៃ ចាត់ទុកដូចជាដុំថ្ម ឬស្លឹកឈើ ឬសំរាមដែលជារបស់គ្មានប្រយោជន៍

ក- មើលឃើញ ភរិយា កូនស្រី ចៅស្រីរបស់ជនដទៃ ចាត់ទុកស្មើនឹងមាតាបង្កើតរបស់ខ្លួន ដែលខ្លួនធ្លាប់ស្រឡាញ់ និងគោរពប៉ុណ្ណា ត្រូវតែស្រឡាញ់ និងគោរពដូច្នោះដែរ

គ- មើលឃើញទុក្ខវេទនា ឈឺចាប់ ក្រីក្រលំបាកតោកយ៉ាករបស់ជនដទៃ ចាត់ទុកស្មើនឹងទុក្ខវេទនា ឈឺចាប់ ក្រតោកយ៉ាករបស់ខ្លួនដែរ គតិបណ្ឌិតទាំង៣ប្រការនេះ បើកាលណាកើតមាននៅលើនរជនណាហើយ នរជននោះរមែងចាត់ទុកជាអ្នកប្រាជ្ញបណ្ឌិតពិតប្រាកដមែន ។

**សេចក្ដីសន្និដ្ឋាន** : មូលហេតុដែលនាំឱ្យសកម្មជន បញ្ញវ័ន្តជាច្រើនលើសលប់ បានយល់ ឃើញ និងមើលឃើញពីលទ្ធផលនៃថ្ងៃទី៧ មករា ឆ្នាំ ១៩៧៩ ថាជាថ្ងៃជោគជ័យរបស់ក្រុមអ្នកបំរើជនជាតិយួនវៀតណាមទៅវិញនោះ ពីព្រោះតែសកម្មជនទាំងនោះបានសិក្សាស្រាវជ្រាវគ្រប់ជ្រុងជ្រោយទៅតាមប្រវត្តិសាស្ត្រ និងទៅតាមភស្តុតាងជាក់ស្ដែងជាច្រើនដែលជាជនជាតិយួននេះ បានរៀបចំគម្រោងផែនការជាច្រើនរយឆ្នាំមកហើយ រហូតមកដល់ថ្ងៃនេះ ជនជាតិយួន នៅតែកំពុងបង្ហាញភស្តុតាងជាក់ស្ដែងនេះ ឱ្យឃើញយ៉ាងប្រត្យក្សជាក់ ស្ដែងពិតប្រាកដមែន ។

- តើមកពីហេតុអ្វី ? បានជាមេដឹកនាំខ្មែរ និងមន្ត្រីគ្រប់លំដាប់ថ្នាក់ ដែលកំពុងកាន់អំណាចសព្វថ្ងៃដែលតែងតាំងឡើងដោយយួននេះ ហ៊ានប្រើអំណាចដ៏ឃោរឃៅ សាហាវព្រៃផ្សៃ ទៅបង្ក្រាបចាប់ចងសកម្មជន ហើយចាត់ទុកជាជនក្បត់ជាតិ ប្រព្រឹត្តអំពើឧក្រិដ្ឋទៅវិញដូច្នេះ ? មានន័យថា មេដឹកនាំនេះ ពុំមែនជាជាតិខ្មែរពិតប្រាកដទេ គឺពិតជាក្រុមអ្នកបំរើជនជាតិយួន ជាអ្នកបង្កឱ្យធ្វើអ្វីៗ មកលើជនជាតិខ្មែរ ស្នេហាជាតិពិតប្រាកដ ឱ្យតែខ្លួនបានបុណ្យស័ក្តិ មានអំណាចជាអធិរាជកំពូល មានទ្រព្យសម្បត្តិ លុយកាក់មហាសាល ។

សរុបសេចក្ដីទៅ មេដឹកនាំរបៀបនេះ មិនអាចចាត់ទុកជាឧត្តមបុគ្គលប្រកបដោយលក្ខណៈសម្បត្តិជាបុគ្គលមានគុណធម៌ សីលធម៌ ជាដើមទៅបានទេ ត្រូវចាត់ទុកថា ជាបុគ្គលប្រកបដោយអគតិ ទុទិដ្ឋិនិយម ជាមិច្ឆាទិដ្ឋិបុគ្គល ហើយត្រូវតែដកហូតចេញពីតំណែងលែងឱ្យកាន់អំណាច ដើម្បីជួយស្រោចស្រង់សង្គ្រោះជាតិ មាតុភូមិឱ្យបានរួចរំដោះពីមហាគ្រោះថ្នាក់មហន្តរាយ **(តទៅទំព័រទី ១៩)**

New World Travel II
ញូវឺលត្រាវែលធូ

Specialized in Selling Flight Tickets
For National and International

ជំនាញខាងលក់សំបុត្រយន្តហោះសំរាប់ក្នុងប្រទេស និងអន្តរជាតិ យើងតំណាងឱ្យក្រុមហ៊ុន ចិន កូរ៉េ កាថេ ។ល។ ធ្វើលិខិត Re-Entry Permit ប្រញាប់ជូនបានទិញសំបុត្រជិះនាវាសមុទ្រ សណ្ឋាគារ ឬជួលឡាន សំបុត្រយន្តហោះទៅច្រើនប្រទេសក្នុងតម្លៃទាបបំផុត ។

Represented Several of Company such as China, Korea, Cathay etc.,
Offer Rush Re-Entry Permit
Reserve Cruise, Hotels and Car Rentals
Best Price Air Ticket for Many Destinations

600 Washington Ave Suite #8
Philadelphia, Pa 19147
Tel: (215) 463-1257
Fax: (215) 463-2036

ខ្មែរប៉ុស្តិ៍
ភាគខាងកើត
THE KHMER POST
EAST COAST
The Cambodian-American Biweekly News
Email : Khmerpostusa@gmail.com
Call : 267-254-8758

Welcome to ២០១០

VOLUME 04 ISSUE 51 January 15th - 28th 2010

# កឹម សុខា នៅសហរដ្ឋអាមេរិក

•••គណបក្សសិទ្ធិមនុស្ស បានរៀបចំបដិសណ្ឋារកិច្ចជូនប្រធានគណបក្សរបស់ខ្លួន គឺលោក កឹម សុខា ដែលទើបនឹងមកពីភ្នំពេញ ដល់ក្រុងហ្វីដែលហ្វៀ រដ្ឋផែនស៊ីវេនា កាលពីថ្ងៃសៅរ៍ ទី៩ មករានេះ ។ លោក កឹម សុខា បានទទួលពរជយន្តោពីព្រះសង្ឃ រួចហើយធ្វើដំណើរគួរសមចំពោះភ្ញៀវប្រមាណ ១៥០នាក់ ដែលបានអញ្ជើញមកចូលរួមនៅភោជនីយដ្ឋានខ្មែរ "ការី" ដែលស្ថិតនៅខាងត្បូងហ្វីឡាដែលហ្វៀ ។



លោក កឹម សុខា ថ្លែងសុន្ទរកថា ទៅកាន់ភ្ញៀវ នៅហ្វីឡាដែលហ្វៀ

លោក ពេជ្រ វិសាកា ប្រធានសាខាប្រចាំរដ្ឋផែនស៊ីវេនា បានឡើងថ្លែងស្វាគមន៍ក្នុងនាមនៃសមាជិកទាំងអស់ មកពីតំបន់ឆ្ងាយជិតជូនដល់ប្រធាន ។ -បន្ទាប់មកលោក ម៉ម យីន ជាទីប្រឹក្សាបានឡើងថ្លែងពីសមត្ថភាពគណបក្សក្នុងរយៈពេលមួយឆ្នាំចុងក្រោយនេះ ។ ពិធីករ ប៊ុនរ៉ាត ម៉ាត ក៏បានអញ្ជើញលោក កឹម សុខា មកថ្លែងសុន្ទរកថារាយការណ៍ពីនយោបាយកម្ពុជា **តទៅទំព័រទី ១០**

# ស្វាគមន៍ឆ្នាំ ២០១០ ក្នុងសន្តិភាព

**ដោយ : ពិន សំខុន**

•••ឆ្នាំថ្មីបានមកដល់ពេញមួយថ្ងៃហើយ នារាត្រីទី១ នៃឆ្នាំ២០១០ នោះ ខ្មែរប៉ុស្តិ៍ បានប្រារព្ធពិធីជប់លៀងជាមួយបងប្អូនខ្មែរ ក្នុងសហគមន៍ ប្រមាណ ១៥០នាក់ នៅភោជនីយដ្ឋាន "ការី" ដែលទើបនិងផ្តើមបើកទ្វារទទួលភ្ញៀវប្រមាណជា២ខែមកហើយ ។ បានបើកទំព័រថ្មីជូនពលរដ្ឋខ្មែរ នៅហ្វីឡាដែលហ្វៀ ថា "ពិភពលោកនេះ និងស្ថិតនៅក្នុងកណ្តាប់ដៃនៃនរណាម្នាក់ដែលហ៊ានក្រោកពីព្រលឹម" ។ នៅថ្ងៃដើមឆ្នាំដែលនឹងបន្តទៅយ៉ាងវែងអន្លាយមិនអាចទប់បានបងប្អូនខ្មែរបានណែនាំគ្នាឱ្យមកជួបជុំជាមិត្តភាពគ្មានបក្សពួក គ្មានកាន់វណ្ណៈ គ្មានកាន់ការប្រកែកប្រកាន់



ឆាករឿងទុំទាវ ដោយ សុភក្រ្ត និង វ៉ានី ដឹកនាំដោយលោក គីម ភឿន

យើងឧទ្ទិសរាត្រីនោះថា ជារាត្រីរបស់សហគមន៍ ជារាត្រីសមោសរនៃសន្តិភាព និងជារាត្រីនៃការអបអរសាទរដល់ក្រុមគ្រួសារខ្លួនឯង ។

ថ្ងៃទី១ ខែមករា ឆ្នាំ២០១០ ធ្លាប់ជាថ្ងៃដ៏ស្ងប់ស្ងាត់ក្នុងទម្លាប់ច្រើនឆ្នាំមកហើយ តែឆ្នាំនេះ ខ្មែរប៉ុស្តិ៍ ហើយលើនេះ ជាពិសេស គ្មានបំណងប្រមូលលុយទៅជួយនរណាក្រៅ ហើយក៏គ្មានប្រាថ្នាអ្វីក្រៅពីការមកកម្សាន្តជាគ្រួសារតែប៉ុណ្ណោះ ។

ខ្មែរប៉ុស្តិ៍ មានបំណងបំពេញតួនាទីមួយថ្មីទៀត

**តទៅទំព័រទី ០៩**

# ៧ មករា នៅហ្វីឡាដែលហ្វៀ

•••មិនមែននៅតែភ្នំពេញទេ ដែលគណបក្សបជាជនប្រារព្ធពិធីជប់លៀង នាឱកាសបុណ្យ ៧ មករា ដែលរំលឹកពីការបណ្តេញប៉ុល ពត ចេញពីអំណាចដោយវៀតណាម នៅហ្វីឡាដែលហ្វៀ សហរដ្ឋអាមេរិក ក៏បានធ្វើពិធីនេះដែរ កាលពីថ្ងៃ ៩ មករា ២០១០មុននេះ នៅភោជនីយដ្ឋាន "ញូគោលដិន ប៉ាលេស" ។ ពិធីនេះចូលរួមដោយលោកឯកអគ្គរាជទូត សៀ កុសល ប្រចាំ អ.ស.ប និងលោកឯកអគ្គរាជទូត ហែម ហេង នៃព្រះរាជាណាចក្រកម្ពុជាប្រចាំរដ្ឋធានីវ៉ាស៊ីនតុនផងដែរ ។


គណកម្មាការនាយកសាខាគណបក្សប្រជាជន នៅហ្វីឡាដែលហ្វៀ នាឱកាសទិវា ៧ មករា

មានភ្ញៀវដ៏គួរឱ្យកត់សំគាល់ក៏បានចូលរួមដែរ គឺ លោក ហ៊ុន ម៉ានី ជាកូនរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងលោក សោម សាត្ថា ហៅម៉ាយារិទ្ធ អតីតបុគ្គលិកអាស៊ីសេរី ***តទៅទំព័រទី ០៧***

